ឯកសារភ្ជាប់

# កិច្ចព្រមព្រៀងស្ដីពីការបង់ប្រាក់ឈ្នួលទៅកាន់គណនីភ្នាក់ងារផ្ទេរប្រាក់
(ឧទាហរណ៍យោង)

(ឈ្មោះនិយោជក) លោក/លោកស្រី

ខ្ញុំ (ឈ្មោះនិយោជិត) បានពិនិត្យមើលខ្លឹមសារទាក់ទងនឹងការបង់ប្រាក់ឈ្នួលទៅកាន់គណនីភ្នាក់ងារផ្ទេរប្រាក់ដែលមានខ្លឹមសារដូចខាងក្រោម៖

☐ និយោជកបានបង្ហាញអំពីជម្រើសនៃវិធីសាស្រ្តបង់ប្រាក់ឈ្នួល រួមមានដូចជា ការបង់ប្រាក់ឈ្នួលទៅកាន់គណនី (តទៅហៅថា «គណនីភ្នាក់ងារផ្ទេរប្រាក់ដែលត្រូវបានកំណត់») របស់ភ្នាក់ងារផ្ទេរប្រាក់ដែលត្រូវបានកំណត់ដោយរដ្ឋមន្រ្តីនៃក្រសួងសុខាភិបាល ការងារ និងសុខុមាលភាព (តទៅហៅថា «ភ្នាក់ងារផ្ទេរប្រាក់ដែលត្រូវបានកំណត់») ព្រមទាំងគណនីសន្សំ (គណនីធនាគារ ។ល។) ឬគណនីមូលបត្រទូទៅ។

☐ ខ្ញុំបានស្ដាប់ការពន្យល់ពីនិយោជក ឬភ្នាក់ងារផ្ទេរប្រាក់ដែលត្រូវបានកំណត់ដោយនាយោជក អំពីខ្លឹមសារទាក់ទងនឹងចំណុចប្រុងប្រយ័ត្ននៅផ្នែកខាងក្រោយ ហើយបានបញ្ជាក់មើលខ្លឹមសារទាំងនោះ។

អាស្រ័យហេតុនេះ ខ្ញុំ (ឈ្មោះនិយោជិត) ធ្វើការជ្រើសរើសការបង់ប្រាក់ឈ្នួលទៅកាន់គណនីផ្ទេរប្រាក់ដូចខាងក្រោម៖

☐ ខ្ញុំ (ឈ្មោះនិយោជិត) បានពិនិត្យមើលខ្លឹមសារខាងក្រោម ហើយបានយល់ព្រមចំពោះការបង់ប្រាក់ឈ្នួលទៅកាន់គណនីភ្នាក់ងារផ្ទេរប្រាក់ដែលបានកំណត់ និងស្នើឲ្យមានការប្រើប្រាស់ដូចខាងក្រោម៖

☐ ខ្ញុំ (ឈ្មោះនិយោជិត) មិនយល់ព្រមឲ្យមានការបង់ប្រាក់ឈ្នួលទៅកាន់គណនីភ្នាក់ងារផ្ទេរប្រាក់ដែលបានកំណត់ទេ។
(ករណីជ្រើសរើសចម្លើយនេះ អ្នកពុំចាំបាច់ធ្វើការបំពេញតទៀតទេ។)

សម្គាល់

1. ទំហំ និងបរិមាណប្រាក់ឈ្នួលដែលចង់ឲ្យផ្ទេរទៅកាន់គណនីភ្នាក់ងារផ្ទេរប្រាក់ដែលបានកំណត់
   ※ គណនីភ្នាក់ងារផ្ទេរប្រាក់ដែលបានកំណត់ត្រូវបានកំណត់ទឹកប្រាក់ទទួលអតិបរមាក្រោម១០០ម៉ឺនយេន។ រីឯទំហំនឹងបរិមាណប្រាក់ឈ្នួលដែលចង់ឲ្យផ្ទេរ
   ចាំបាច់ត្រូវធ្វើការកំណត់ដោយពិនិត្យមើលចំណុចប្រុងប្រយ័ត្ននៅផ្នែកខាងក្រោយ «2. ប្រាក់នៅក្នុងគណនីភ្នាក់ងារផ្ទេរប្រាក់»។
   ក. ប្រាក់ឈ្នួលទៀងទាត់ យេន
   ខ. ប្រាក់រង្វាន់ យេន
   គ. ប្រាក់បំណាច់ យេន
2. ឈ្មោះភ្នាក់ងារផ្ទេរប្រាក់ដែលត្រូវបានកំណត់ ឈ្មោះសេវាកម្ម លេខគណនី (Account ID) និងឈ្មោះអ្នកទទួល (ចំណុចផ្សេងៗពាក់ព័ន្ធនឹងព័ត៌មានចាំបាច់ដើម្បីកំណត់ជាពិសេសទៅលើគណនីផ្សេងៗ)ដែលត្រូវបានកំណត់ដោយនិយោជិត

   ឈ្មោះភ្នាក់ងារផ្ទេរប្រាក់ដែលបានកំណត់៖
   ឈ្មោះសេវាកម្មផ្ទេរប្រាក់៖
   លេខគណនី (Account ID)៖
   ឈ្មោះអ្នកទទួល៖
   (ព័ត៌មានចាំបាច់ដើម្បីកំណត់ជាពិសេសទៅលើគណនីប្រសិនបើមានការចាំបាច់ (ឧទាហរណ៍៖ លេខទូរស័ព្ទរបស់និយោជិត ។ល។))
3. កាលបរិច្ឆេទចង់ឲ្យចាប់ផ្ដើមបង់ប្រាក់ទៅកាន់គណនីភ្នាក់ងារផ្ទេរប្រាក់ដែលបានកំណត់

   ឆ្នាំ ខែ ថ្ងៃទី
4. ព័ត៌មានគណនីជំនួសរួមមានដូចជា ឈ្មោះសាខាស្ថាប័នហិរញ្ញវត្ថុដែលបានកំណត់ ប្រភេទប្រាក់បញ្ញើ ឬប្រភេទនៃការសន្សំ និងលេខគណនី ឬឈ្មោះសាខារបស់ក្រុមហ៊ុនមូលបត្រដែលបានកំណត់ និងលេខគណនីមូលបត្រទូទៅ ព្រមទាំងឈ្មោះអ្នកទទួល

   ※ គណនីនេះនឹងត្រូវបានប្រើប្រាស់សម្រាប់ករណីនិយោជិតទទួលយកប្រាក់ដែលមានចំនួនលើសអតិបរិមានៅពេលមានទឹកប្រាក់លើសពីកម្រិតនៃការទទួលរបស់គណនីភ្នាក់ងារផ្ទេរប្រាក់ដែលបានកំណត់ ឬករណីទទួលប្រាក់ទូទាត់ពីស្ថាប័នធានានៅពេលភ្នាក់ងារផ្ទេរប្រាក់ដែលបានកំណត់ក្ស័យធន។

   ឈ្មោះសាខាស្ថាប័នហិរញ្ញវត្ថុ ឬឈ្មោះសាខាក្រុមហ៊ុនមូលបត្រ៖
   លេខគណនី៖
   ឈ្មោះអ្នកទទួល៖

ឆ្នាំ ខែ ថ្ងៃទី

ឈ្មោះ

ចំណុចប្រុងប្រយ័ត្នពាក់ព័ន្ធនឹងការបង់ប្រាក់ទៅកាន់គណនីភ្នាក់ងារផ្ទេរប្រាក់

យោងតាមច្បាប់ (ច្បាប់លេខ៥៩ ឆ្នាំ២០០៩។ តទៅហៅថា«ច្បាប់ស្តីពីការទូទាត់ប្រាក់») ស្តីពីការទូទាត់ប្រាក់ ភ្នាក់ងារផ្ទេរប្រាក់ត្រូវធ្វើការចុះបញ្ជីដោយនាយករដ្ឋមន្ត្រី (ផ្ទេរសិទ្ធិទៅកាន់អគ្គនាយកនៃនាយកដ្ឋានហិរញ្ញវត្ថុ) ហើយគឺជាអ្នកប្រកបអាជីវកម្មប្តូររូបិយប័ណ្ណ និងជាអ្នកស្ថិតនៅក្រៅស្ថាប័នហិរញ្ញវត្ថុផ្សេងទៀត ឬធនាគារ។

【1. ការព្រមព្រៀងរបស់និយោជិត】

និយោជក ឬភ្នាក់ងារផ្ទេរប្រាក់ដែលត្រូវបានកំណត់ដោយនិយោជក ត្រូវពន្យល់អំពីចំណុចដែលបានពណ៌នាខាងក្រោមទៅកាន់និយោជិត។ ដោយឡែក ពេលធ្វើការបង់ប្រាក់ទៅកាន់គណនីភ្នាក់ងារផ្ទេរប្រាក់ និយោជកត្រូវបង្ហាញអំពីជម្រើសនៃវិធីសាស្រ្តបង់ប្រាក់ឈ្នួលទៅកាន់និយោជិត រួមមានដូចជា ការបង់ជាប្រាក់សុទ្ធ ឬបង់តាមគណនីភ្នាក់ងារផ្ទេរប្រាក់ ព្រមទាំងគណនីសន្សំ (គណនីធនាគារ) ឬគណនីមូលបត្រទូទៅ។ ប្រសិនបើនិយោជកធ្វើការបង្ហាញអំពីជម្រើសនៃវិធីសាស្រ្តបង់ប្រាក់ទៅនិយោជិតតែ២ជម្រើសដូចជា បង់តាមប្រាក់សុទ្ធ ឬគណនីភ្នាក់ងារផ្ទេរប្រាក់ ឬគ្រាន់តែធ្វើការបង្ហាញជាចម្រើសតែជាក់ស្តែងមានការបង្ខិតបង្ខំឲ្យនិយោជិតទទួលយកការបង់ប្រាក់តាមគណនីភ្នាក់ងារផ្ទេរប្រាក់ នោះគឺល្មើសនឹងមាត្រាទី២៤នៃច្បាប់ស្តីពីស្តង់ដារការងារ (ច្បាប់លេខ៤៩ ឆ្នាំ១៩៤៧) ហើយនិយោជកត្រូវទទួលការពិន័យ។

【2. ប្រាក់នៅក្នុងគណនីភ្នាក់ងារផ្ទេរប្រាក់】

ប្រាក់នៅក្នុងគណនីភ្នាក់ងារផ្ទេរប្រាក់គឺខុសពី«ប្រាក់បញ្ញើ»នៅក្នុងគណនីសន្សំ ហើយវាត្រូវបានប្រើប្រាស់សម្រាប់គោលបំណងជួញដូររូបិយប័ណ្ណ (ការផ្ទេរប្រាក់ និងការទូទាត់។ល។)។ នៅពេលនិយោជិតប្រើប្រាស់សេវាកម្មបង់ប្រាក់ទៅកាន់គណនីភ្នាក់ងារផ្ទេរប្រាក់ ចំនួនទឹកប្រាក់ផ្ទេរទៅកាន់គណនីគឺត្រូវស្ថិតក្នុងបរិវេណប្រើសម្រាប់ជួញដូររូបិយប័ណ្ណ (ការផ្ទេរប្រាក់ និងការទូទាត់។ល។) ហើយមិនត្រូវឲ្យមានសល់ប្រាក់ដែលមិនចាំបាច់ប្រើសម្រាប់ការផ្ទេរប្រាក់ និងការទូទាត់ទេ។ អាស្រ័យហេតុនេះ ចំពោះចំនួនទឹកប្រាក់ (ចំនួនចង់ផ្ទេរ។ល។) និងទំហំទឹកប្រាក់ដែលចង់ផ្ទេរទៅកាន់គណនីរបស់ភ្នាក់ងារផ្ទេរប្រាក់ ចាំបាច់ត្រូវស្ថិតក្នុងតួរលេខជាក់ស្តែង ឬតួរលេខគ្រោងនឹងធ្វើការផ្ទេររបស់និយោជិត។ ដោយឡែក ពេលកំណត់ចំនួនទឹកប្រាក់ចង់ផ្ទេរ ចាំបាច់ត្រូវធ្វើការកំណត់តួរលេខឲ្យស្ថិតនៅក្រោមចំនួនអតិបរិមានៃសមតុល្យគណនី (ក្រោម១០០ម៉ឺនយេន) និងទឹកប្រាក់អតិបរិមាផ្ទេរចេញក្នុង១ថ្ងៃដែលភ្នាក់ងារផ្ទេរបានកំណត់។

ចំណែកឯគណនីភ្នាក់ងារផ្ទេរប្រាក់ដែលត្រូវបានទទួលស្គាល់ឲ្យបង់ប្រាក់ឈ្នួល ទឹកប្រាក់អតិបរិមាទទួលគឺត្រូវនៅក្រោម១០០ម៉ឺនយេន)។ អាស្រ័យហេតុនេះ ចាំបាច់ត្រូវចុះបញ្ជីឡើងវិញនូវព័ត៌មានឈ្មោះស្ថាប័នហិរញ្ញវត្ថុ ឬឈ្មោះក្រុមហ៊ុនមូលបត្រ និងលេខគណនីសម្រាប់ផ្ញើប្រាក់នៅពេលហួសចំនួនទឹកប្រាក់អតិបរិមាទទួលរបស់គណនីនៅពេលបង់ប្រាក់ឈ្នួល។ ប្រសិនបើករណីលើសចំនួនអតិបរិមាទទួល ភ្នាក់ងារផ្ទេរប្រាក់នឹងផ្ញើប្រាក់ទៅកាន់គណនីសន្សំដែលបានចុះបញ្ជីនោះ ប៉ុន្តែ អាចនឹងតម្រូវឲ្យអ្នកទទួលរ៉ាប់រងលើថ្លៃសេវាផ្ញើប្រាក់នាពេលនោះ។

【3. ការធានានៅពេលភ្នាក់ងារផ្ទេរប្រាក់បានក្ស័យធន】

ករណីភ្នាក់ងារហិរញ្ញវត្ថុដូចជាធនាគារមានការក្ស័យធន យោងតាមប្រព័ន្ធធានារ៉ាប់រងប្រាក់បញ្ញើដែលផ្អែកតាមច្បាប់ធានារ៉ាប់រងលើប្រាក់បញ្ញើ ទឹកប្រាក់ដែលស្ថិតក្នុងកម្រិតកំណត់ណាមួយនឹងត្រូវបានការពារ ប៉ុន្តែ ប្រសិនបើភ្នាក់ងារផ្ទេរប្រាក់ដែលត្រូវបានទទួលស្គាល់ឲ្យបង់ប្រាក់ឈ្នួលមានការក្ស័យធន នោះគឺស្ថិតនៅក្រៅប្រព័ន្ធធានារ៉ាប់រងប្រាក់បញ្ញើ។ ករណីភ្នាក់ងារផ្ទេរប្រាក់ក្ស័យធន នឹងមានការទូទាត់សងនូវទឹកប្រាក់ទាំងអស់នៃសមតុល្យគណនីទៅកាន់និយោជិតវិញយ៉ាងឆាប់ ដោយផ្អែកតាមកិច្ចសន្យាធានារបស់និយោជិត និងស្ថាប័នធានា ហើយការទូទាត់នេះនឹងត្រូវបានធ្វើឡើងដោយស្ថាប័នធានាដែលបានភ្ជាប់កិច្ចសន្យាធានាជាមួយភ្នាក់ងារផ្ទេរប្រាក់។

【4. សំណងក្នុងករណីមានការក្លែងបន្លំការដកប្រាក់ពីគណនីភ្នាក់ងារផ្ទេរប្រាក់】

ករណីប្រាក់នៅក្នុងគណនីភ្នាក់ងារផ្ទេរប្រាក់ដែលត្រូវបានទទួលស្គាល់ឲ្យបង់ប្រាក់ឈ្នួល ត្រូវបានដកចេញខុសប្រក្រតីដោយសារអ្នកដែលគ្មានសិទ្ធិហើយប្រឆាំងនឹងឆន្ទៈរបស់និយោជិត ប្រសិនបើនិយោជិតមិនមានកំហុសទេ ចំនួនទឹកប្រាក់នៃការបាត់បង់ពេញលេញនឹងត្រូវបានផ្តល់សំណង។ ដោយឡែក ទោះបីជាករណីនិយោជិតមានកំហុសក៏ដោយ មិនមែនមានន័យថាការបាត់បង់នឹងមិនត្រូវបានផ្តល់សំណងទាល់តែសោះនោះទេ អាចនឹងមានការដោះស្រាយតាមបុគ្គល។ ដោយឡែក ចំណាត់ការនេះនឹងមិនត្រូវបានអនុវត្តចំពោះករណីសងប្រាក់វិញដោយសាច់ញាតិរបស់និយោជិត។ល។ ហើយនិយោជិតបានផ្តល់ការពន្យល់មិនពិតទៅកាន់ភ្នាក់ងារផ្ទេរប្រាក់។ លើសពីនេះទៅទៀត ករណីមានការតម្រូវជាលក្ខខណ្ឌសំណងដោយភ្នាក់ងារផ្ទេរប្រាក់ ដោយឲ្យនិយោជិតធ្វើការជូនដំណឹងទៅកាន់ភ្នាក់ងារផ្ទេរប្រាក់ក្នុងថេរវេលាកំណត់ណាមួយចាប់ពីថ្ងៃខាតបង់ ថេរវេលានោះយ៉ាងហោចណាស់ត្រូវមានរយៈពេលលើសពី៣០ថ្ងៃគិតចាប់ពីថ្ងៃបាត់បង់។

【5. បំណុលក្នុងករណីមិនបានប្រើប្រាស់ប្រាក់នៅក្នុងគណនីភ្នាក់ងារផ្ទេរប្រាក់ក្នុងថេរវេលាកំណត់ណាមួយ】

ចំពោះសមតុល្យគណនីភ្នាក់ងារផ្ទេរប្រាក់ដែលត្រូវបានទទួលស្គាល់ឲ្យបង់ប្រាក់ឈ្នួល ករណីភ្នាក់ងារផ្ទេរប្រាក់បានធ្វើការកំណត់រយៈពេលសុពលភាពតាមរយៈកិច្ចសន្យាប្រើប្រាស់ គិតចាប់ពីថ្ងៃប្រែប្រួលចុងក្រោយនៃសមតុល្យគណនី យ៉ាងហោចណាស់ក្នុងរយៈពេល១០ឆ្នាំ ត្រូវប្រតិបត្តិកាតព្វកិច្ចបំណុល។

【6. លទ្ធភាពសាច់ប្រាក់នៅក្នុងគណនីភ្នាក់ងារផ្ទេរប្រាក់】

ប្រាក់នៅក្នុងគណនីភ្នាក់ងារផ្ទេរប្រាក់ដែលត្រូវបានទទួលស្គាល់ឲ្យបង់ប្រាក់ឈ្នួល អាចផ្ទេរបានក្នុងឯកតា១យេនចេញពីគណនីភ្នាក់ងារផ្ទេរប្រាក់តាមរយៈមធ្យោបាយដែលអាចទទួលរូបិយប័ណ្ណទៅកាន់គណនីបញ្ញើ និងម៉ាស៊ីនទូទាត់ប្រាក់សុទ្ធដោយស្វ័យប្រវត្ត (CD) ឬម៉ាស៊ីនបេឡាករដោយស្វ័យប្រវត្តិ (ATM)។ លើសពីនេះទៀត និយោជិតអាចផ្ទេរប្រាក់ចេញពីគណនីភ្នាក់ងារផ្ទេរប្រាក់យ៉ាងហោចណាស់១ដងជារៀងរាល់ខែ ដោយមិនត្រូវឲ្យបង់ថ្លៃសេវា។